ក

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៤-១០-២០១០-ព្រះរាជក្រឹត្យ នស/រកត/១០១០/៧៩៩ ស្តីពី ការតែងតាំងឯកឧត្តម សាន ខណ្ឌាស៊ី ជា ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈ ស្មើ រដ្ឋលេខាធិការ ៨១៣២

១៤-១០-២០១០-ព្រះរាជក្រឹត្យ នស/រកត/១០១០/៨០០ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម សួន ផល្លី ពីទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈ ស្មើ អនុរដ្ឋលេខាធិការ ៨១៣៣


## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២០-១០-២០១០ -អនុក្រឹត្យលេខ ១៣៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨១៣៤

២០-១០-២០១០ -អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨១៣៦

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨១៣៨

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨១៣៩

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៤១

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៨១៤៣

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៤៥

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨១៤៦

១៩-១០-២០១០ -អនុក្រឹត្យលេខ ១០១៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨១៤៧


## III.ការិយាល័យក្រសួង

### ១.ទីស្តីការក្រសួងមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


១០-៩-២០១០ -ប្រកាសលេខ ៥៧៩ ប្រក.កសក ស្តីពី ការចុះបញ្ជីសហគមន៍នេសាទខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះសីហនុ កណ្តាល កោះកុង តាកែវ ព្រៃវែង និង ខេត្តស្ទឹងត្រែង ៨១៤៨

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០២៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គ្រូបផេច គ្រេន ឡូជីស្ទីគ ៨១៥៦

១៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០២៩៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ដ្យាយអិន ហ្គោលឌិន អ៊ិន ខេសមេន ខូ អិលធីឌី ៨១៥៨

១៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០២៩៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌី ធើរេស វ៉ៃញ្ជូត ៨១៦០

១៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០២៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេច. ខេ. អាយ. អ៊ីមផត អិចផត ៨១៦២

១៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៣០៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ែន & ហ្គោល រីសស៍ (ខេមបូឌា) ៨១៦៤

# ព្រះរាជក្រឹត្យ

នស/រកត/១០១០/៧៩៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **សាន ចណ្ណាស៊ី** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១០១០. ៩១៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១០*

លេខ: ៧៧០ ច.ល
បានឃើញដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០១០/៩០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ចប់មុខតំណែង ឯកឧត្តម សួន ផល្លី ពីទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.១០១០.៩១៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០

លេខ: ៧៦៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០១០
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ប៊ុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៣៣ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/១២០៩/០២៦ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៨ អនក្រ.បក , ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយចរន្តទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ១.៣៣៩.៥៧០.០០០រៀល (មួយពាន់បីរយសាមសិបប្រាំបួនលានប្រាំរយចិតសិបពាន់រៀលគត់) ពីជំពូក៦០(ការទិញ) ចំនួន៥៧០.៣៦០.០០០រៀល(ប្រាំរយចិតសិបលានបីរយហុកសិបពាន់រៀលគត់)ជំពូក៦១(សេវាខាងក្រៅ)ចំនួន៧៦៩.២១០.០០០រៀល(ប្រាំពីររយហុកសិបប្រាំបួនលានពីររយដប់ពាន់រៀលគត់) មកជំពូក៦២(សេវាខាងក្រៅផ្សេងៗ)ចំនួន១.២៦២.៥៧០.០០០រៀល(មួយពាន់ពីររយហុកសិបពីរលានប្រាំរយចិតសិបពាន់រៀលគត់) និងជំពូក៦៥(ឧបត្ថម្ភកធន និងជំនួយសង្គម) ចំនួន ៧៧.០០០.០០០រៀល(ចិតសិបប្រាំពីរលានរៀលគត់) ជូនក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ទូទាត់សោហ៊ុយបេសកកម្មក្នុងប្រទេសជូនថ្នាក់ដឹកនាំ និងមន្ត្រីដែលបានចុះបំពេញការងារតាមបណ្តារាជធានី-ខេត្តក្រុង និងឧបត្ថម្ភការដោះលែងអ្នកទោសចំនួន៧៧១នាក់ ឆ្នាំ២០១០ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ៨០៦ លានរៀល ( ប្រាំបីរយប្រាំមួយលានរៀលគត់) ពីជំពូក ០៩ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ ( ការទិញ-ថវិកាកម្មវិធី) ចំនួន ៥៦ លានរៀល ជំពូក ៦១ ( សេវាខាងក្រៅ-ថវិកាកម្មវិធី ) ចំនួន ៩៤ លានរៀល និងមកជំពូក ៦២ ( សេវាខាងក្រៅផ្សេងៗ-ថវិកាកម្មវិធី ) ចំនួន ៦៥៦ លានរៀល ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់អនុវត្តការងារធ្វើអត្តសញ្ញាណកម្មលំអិតទីតាំងដី ៤៩ ទីតាំង នៅខេត្តចំនួន ១៦ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០១៧ .អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០៧ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសការងារ ចំនួន ០៣ គ្រឿង ជូនមន្ត្រីអង្គការយូនីសេហ្វ ចំនួន ០៣រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារជួយដល់កុមារ នៅព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | ម៉ែន សេដ្ឋារតន៍ | មន្ត្រីការពារកុមារ | អង្គការយូនីសេហ្វ |
| ២- | លោក | កែវ ម៉េងឡាង | ជំនួយការកម្មវិធី | អង្គការយូនីសេហ្វ |
| ៣- | លោក | ឈាង ឡូ | ទីប្រឹក្សាផ្នែកការពារកុមារ | អង្គការយូនីសេហ្វ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១៧ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១០១៤.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីក្រុមការងារ ចំនួន២៧រូប ដែលបានខិតខំអស់ពីកម្លាំងកាយ ចិត្ត និងថវិកា ចូលរួមកសាងសមិទ្ធផលនានា រួមចំណែកក្នុងការអភិវឌ្ឍន៍ស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | អ៊ុំ សារឿន | មេឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២-លោក | នាង ឈឿម | ជំទប់ទី១ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៣-លោក | នេស ស៊ីត | ក្រុមប្រឹក្សា ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៤-លោក | ធ្នាក់ តិរុណ | ក្រុមប្រឹក្សា ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៥-លោក | ហ៊ិន សា | ក្រុមប្រឹក្សា ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៦-លោក | នឹម នួច | ក្រុមប្រឹក្សា ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៧-លោកស្រី | ជឹម ឆន់ | ក្រុមប្រឹក្សា ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៨-លោកស្រី | រ៉ុំ ចាន់ នី | ស្មៀនឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ៩-លោក | ហាំង ផល្លី | ប្រធានក្រុមការងារភូមិថែងក្តារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១០-លោក | អេង ជាត់ | ប្រធានក្រុមការងារ ភូមិកំប៉ូវ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |

| | | |
|---|---|---|
| ១១-លោក | គួច យ៉ីន | ប្រធានក្រុមការងារ ភូមិគោកអំពិល ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១២-លោក | យ៉ាត យឿត | ប្រធានក្រុមការងារ ភូមិសំពៅកើត ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៣-លោក | ថោង ឈឿម | ប្រធានក្រុមការងារ ភូមិសំពៅលិច ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៤-លោក | តែ ឆប | ប្រធានក្រុមការងារ ភូមិក្តោង ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៥-លោក | ញឹម បូ | ប្រធានក្រុមការងារ ភូមិសំណាញ់ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៦-លោក | ឆន់ ឆម | ប្រធានក្រុមការងារ ភូមិក្រពើជើង ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៧-លោក | ឆែម នាត | ប្រធានក្រុមការងារ ភូមិក្រពើត្បូង ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៨-លោក | សំ នៅ | ប្រធានក្រុមការងារ ភូមិក្រពើកើត ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ១៩-លោក | សេង ម៉ុនស៊ី | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២០-លោក | អ៊ែល អាន | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២១-លោក | ចាន់ ណៃ | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២២-លោក | ចាន់ ចេង | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២៣-លោក | ដាំ ឆាង | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២៤-លោក | លី សុខគួង | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២៥-លោក | ពិន ឌុំ | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២៦-លោក | គុន ម៉ុនដារ៉ា | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |
| ២៧-លោក | ម៉ៅ មុនីកេសរ៉ា | សមាជិកក្រុមការងារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង |

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០១៥. អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយ នាយរងនគរបាលជាតិ ចំនួន២៣រូប ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តនិងថវិកា ចូលរួមចំណែកជួយកសាងសមិទ្ធផលនានា នៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទៈ**

| | |
|---|---|
| ១-លោក ខួន ទើងគួន | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងផ្លុង ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ២-លោក កែវ តាយ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៣-លោក អ៊ុំ រិទ្ធា | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៤-លោក អ៊ី សំណាង | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៥-លោក អ៊ុំ យឹង | នាយផ្នែកច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៦-លោក ស៊ុក ផាឡាដែត | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបាវិត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៧-លោក កែវ តិស៊ីម | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងផ្លុងន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |
| ៨-លោកស្រី ជា ផានី | មន្ត្រីប៉ុស្តិ៍ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

| | | |
|---|---|---|
| ១-លោក | អឿន សារុន | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង |
| ២-លោក | សុខ តុលា | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង |
| ៣-លោក | ថន ស៊ីថា | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងផ្លុងន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |
| ៤-លោក | ចេង សម្បត្តិ | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងផ្លុងន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |
| ៥-លោក | ហែម វិបុឡា | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៦-លោក | ស៊ឹម ស៊ិន | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៧-លោកស្រី | បាន ស្រីមាស | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបាវិត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៨-លោក | យូ ដាគង់ | មន្ត្រីប៉ុស្តិ៍ ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

| | | |
|---|---|---|
| ១-លោក | ជឹម តារាម្សៀ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ២-លោក | អេង សុវណ្ណ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៣-លោក | សួន សុវណ្ណ | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |
| ៤-លោក | សាន់ ទេងសៀង | នាយផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៥-លោក | ស យុណេត | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |
| ៦-លោក | រស់ សារុំ | នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |
| ៧-លោក | នួច ហ៊ី | មន្ត្រីប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ន.ដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ក.ញ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១០១៦ . អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូននាយ នាយរងនគរបាលជាតិ ចំនួន២៣រូប ដែលបានខិតខំអស់ពីកម្លាំង កាយចិត្ត និងថវិកា ចូលរួមចំណែកជួយកសាងសមិទ្ធផលនានា នៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ:**

| | | |
|---|---|---|
| ១-លោក | អ៊ិត ចេតនា | នាយការិយាល័យ នាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ២-លោក | សួន គគ្គី | នាយរងការិយាល័យច្រកទ្វារព្រំដែន នាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៣-លោក | ហង្ស ជឿន | នាយរងការិយាល័យច្រកទ្វារព្រំដែន នាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៤-លោក | ទិន លីណាហ្វានណូ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៥-លោក | រឹម លឹមសេង | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៦-លោក | ស៊ិន សុធី | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបាវិត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៧-លោក | ទ្រាក់ វុត្ថា | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៨-លោក | ខាត់ សុខ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ៩-លោក | ជុំល ជុំ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |
| ១០-លោក | អ៊ុម ទុធ | នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ |

១១-លោក ម៉ិច រី នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
១២-លោក ជាម ដារ៉ា នាយផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងផ្លុង ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
១៣-លោក ង៉ែ តិស្សរា នាយផ្នែកការិយាល័យច្រកទ្វារព្រំដែន នាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ

ខ-មេដាយសុវត្ថារា ថ្នាក់ សេនា:

១-លោក ឆេត ចន្ទូ នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
២-លោក ជា ដារ៉ា នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
៣-លោក ជួន សារី នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
៤-លោក តឹប យ៉ាឌី នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
៥-លោក នុប ចន្ថា នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិព្រៃកចាក ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
៦-លោក អ៊ឹម សារដ្ឋ នាយការិយាល័យ នៃស្នងការដ្ឋាននគរបាល ខេត្តបាត់ដំបង
៧-លោក សៀម ចន្ថា មន្ត្រីប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបារិត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ

គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ:

១-លោក ហេង ម៉ិនស្រ៊ុន នាយផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
២-លោក សារី សំរុង នាយរងផ្នែកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិសៀមរាប ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
៣-លោកស្រី ហែម ចន្ថា មន្ត្រីប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិបារិត ន.ដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ១៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១០១៧.អនក្រ.តត**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា ជូនមន្ត្រីរាជការ ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការ ចូលរួមចំណែកសាងសង់អគារថ្មី នៃទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម៖

១-លោក **ពិន សុធា** មន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាជំនួយការលេខាធិការដ្ឋានអចិន្ត្រៃយ៍

២-លោក **លឹម ឈុនលាង** មន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាជំនួយការលេខាធិការដ្ឋានអចិន្ត្រៃយ៍

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ[illegible] ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១០១៧ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង អគារសិក្សា ០២ខ្នង មាន ០៨បន្ទប់ និងចាក់ដីបំពេញទីធ្លាសាលា ស្ថិតក្នុងស្រុកឈូក និង អគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ បំពាក់សំភារៈគ្រប់គ្រាន់ ស្ថិតក្នុងស្រុកដងទង់ ខេត្តកំពត ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១- | លោក | អ៊ុន ដារី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.០០០ ដុល្លារ |
| ២- | អ្នកស្រី | លី សុវណ្ណា | សប្បុរសជនខ្មែររស់នៅប្រទេសបារាំង | ថវិកា ១០.០០០ ដុល្លារ |
| ៣- | លោក | ហ៊ុក សុទ្ធិ | តំណាងអង្គការស៊ីប៉ា នៅរាជធានីភ្នំពេញ | ថវិកា ១០.០០០ ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| - | លោក | កែវ ថន | សប្បុរសជននៅខេត្តកំពត | ថវិកា ១.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ... ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០១៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ទ៉ាន់ សួន** គង់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគបច្ច័យជួយជួសជុលផ្លូវលំ ក្រាលគ្រួសក្រហម ០១ខ្សែ ប្រវែង ៤.០០០ ម៉ែត្រ និងធ្វើលូកាត់ ផ្លូវមួយកន្លែង នៅក្នុងភូមិគោកសំរោង ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចំណាយអស់បច្ច័យ សរុបចំនួន ១២.៤០០ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៧៩ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីសហគមន៍នេសាទខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះសីហនុ កណ្តាល កោះកុង តាកែវ ព្រៃវែង និង ខេត្តស្ទឹងត្រែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នសរកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

# សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការ និង ទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នូវសហគមន៍នេសាទចំនួន ៦៣ ក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះសីហនុ កណ្ដាល កោះកុង តាកែវ ព្រៃវែង និង ខេត្តស្ទឹងត្រែង ដែលមានឈ្មោះសហគមន៍នេសាទ ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និង ទីតាំងភូមិសាស្ត្រ ដូចមាននៅក្នុងតារាង និង ផែនទីកន្លែងនេសាទសហគមន៍នីមួយៗ ជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និង ទីតាំងភូមិសាស្ត្ររបស់សហគមន៍ ដូចមានចែងក្នុងប្រការ ១ អាចកែប្រែបានតាមការចាំបាច់ ។

**ប្រការ ៤.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

